ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៤ អសរណ

# សារាចរណែនាំ
## ស្តីពី
## ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី១៣១ នៃទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា តែងរៀបចំប្រារព្ធទិវាពលកម្មអន្តរជាតិ ១ ឧសភា ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី០១ ខែឧសភា ជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការ និងកម្មករនិយោជិតទាំងអស់ ដូចថ្ងៃបុណ្យជាតិ បុណ្យប្រពៃណី និងបុណ្យអន្តរជាតិនានាដែរ។

ទិវាពលកម្មអន្តរជាតិ ១ ឧសភា នាឆ្នាំនេះប្រារព្ធឡើងក្រោមប្រធានបទ «**ដើម្បីសន្តិភាព ការងារ មុខរបរ និងអភិវឌ្ឍន៍**» សំដៅពង្រឹងភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ ការធានាបាននូវស្ថិរភាពវិនិយោគ ភាពប្រកួតប្រជែង និងគុណភាពផលិតផល ការកែលម្អជីវភាពរបស់កម្មករនិយោជិត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។

ដើម្បីរៀបចំការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣១ នៃទិវាពលកម្មអន្តរជាតិថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧នេះ ឱ្យប្រព្រឹត្តទៅបានល្អប្រសើរថែមទៀត រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដូចខាងក្រោម៖

១-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវធ្វើជាស្ថាប័នស្នូលក្នុងការរៀបចំទិវា ដោយចេញសេចក្តីជូនដំណឹងដល់គ្រប់មន្ទីររាជធានី-ខេត្តក្រោមឱវាទ អង្គការវិជ្ជាជីវៈរបស់និយោជក ម្ចាស់និងនាយកសហគ្រាស គ្រឹះស្ថានអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ព្រមទាំងកម្មករនិយោជិតទាំងអស់ ដើម្បីណែនាំអំពីការឈប់សម្រាក និងការរៀបចំកម្មវិធីកំសាន្តសប្បាយតាមលទ្ធភាពរៀងៗខ្លួន នៅតាមសហគ្រាសគ្រឹះស្ថាននានា សំដៅបង្កបរិយាកាសយោគយល់គ្នារវាងកម្មករនិយោជិត និងនិយោជក។ ទន្ទឹមនឹងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវរៀបចំពិធីថ្នាក់ជាតិ ដែលមានការចូលរួមពីតំណាងក្រសួងស្ថាប័នរដ្ឋ តំណាងអង្គការវិជ្ជាជីវៈ តំណាងអង្គការជាតិ និងអន្តរជាតិដែលជាដៃគូ។ ជាមួយគ្នានេះគណៈអភិបាលរាជធានី ខេត្តទាំងអស់ ត្រូវចាត់តាំងរៀបចំពិធីសំណេះសំណាលជាមួយតំណាងកម្មករនិយោជិត នៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថានតាមស្ថានភាពជាក់ស្តែង។

២-ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរដែនដីរាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធានារក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ក្នុងឱកាសនៃការប្រារព្ធទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០១៧ នេះ។

៣-ក្រសួងព័ត៌មាន ត្រូវណែនាំប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជនឱ្យធ្វើការផ្សព្វផ្សាយសារលិខិតរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣១ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា និងសកម្មភាពមិទ្ទីញ ការកំសាន្តសប្បាយនានា របស់កម្មករនិយោជិត និយោជកនៅតាមសហគ្រាស គ្រឹះស្ថាននានា។

៤-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កលក្ខណៈងាយស្រួល ក្នុងការផ្តល់ថវិកាសម្រាប់ការរៀបចំប្រារព្ធទិវាពលកម្មអន្តរជាតិ ១ ឧសភា នេះ។

៥-រាជធានីភ្នំពេញ និងខេត្តទាំងអស់ ក៏ដូចជាក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងសហគ្រាស គ្រឹះស្ថានឯកជន ត្រូវជ្រើសរើសទីតាំងសមស្រប ដូចជាដងវិថីសំខាន់ៗ និងទីតាំងសហគ្រាស គ្រឹះស្ថាន ការដ្ឋាន និងកសិដ្ឋាន ដើម្បីធ្វើការចងបដាពាក្យស្លោកតាមខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣១ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា
- ដើម្បីសន្តិភាព ការងារ មុខរបរ និងអភិវឌ្ឍន៍
- ខិតខំកសាងភាពសុខដុមរមនា រវាងនិយោជក និងកម្មករនិយោជិតនៅតាមសហគ្រាស និងគ្រឹះស្ថាន។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និយោជក កម្មករនិយោជិតកម្ពុជា និងពលករបរទេសទាំងអស់ ចូលរួមប្រារព្ធនិងអបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្នុងបរិយាកាសសោមនស្សរីករាយ សាមគ្គីភាព និងភាតរភាព ដើម្បីឱ្យស័ក្តិសមជាបុណ្យការងាររបស់ជាតិយើង។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានីខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ